# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា

## ការិយាល័យអគ្គនាយកក្រសួងអប់រំ

**440 NORTH BROAD STREET, SUITE 301**
**PHILADELPHIA, PENNSYLVANIA 19130**

WILLIAM R. HITE, JR., Ed.D.
*អគ្គនាយក*

ទូរស័ព្ទ៖ (២១៥) ៤០០-៤១០០
ទូរសារ៖ (២១៥) ៤០០-៤១០៤

ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣

ជូនចំពោះ មាតាបិតា និងអាណាព្យាបាល៖

ដោយរដូវក្តៅនេះខិតជិតមកដល់ហើយ ខ្ញុំចង់ជូនដំណឹងដល់លោកអ្នកអំពីកម្មវិធីល្អៗសម្រាប់ក្មេង តាមរយៈការឧបត្ថម្ភពី ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា អង្គការរបស់ក្រុង និងអង្គការមិនយកកម្រៃនៅក្នុងតំបន់។

វិបសៃនៃកម្មវិធីនៅរដូវក្តៅរបស់ក្រសួងអប់រំ (www.philasd.org/summerprograms) មានព័ត៌មានអំពី សកម្មភាពសិក្សាបន្ថែម កម្មវិធីដែលឧបត្ថម្ភដោយ ដៃគូនៅក្នុងសហគមន៍ និងបញ្ជីឈ្មោះសៀវភៅសម្រាប់អាន សម្រាប់សិស្សានុសិស្សថ្នាក់មុនមត្តេយ្យ ដល់ថ្នាក់ទី១១។ លោកអ្នកអាចមើលព័ត៌មានលម្អិតអំពីអ្វីៗដូចខាងក្រោមនេះ៖

- **កម្មវិធីសម្រាប់យុវវ័យ នៃទីក្រុងហ្វីឡាដែលហ្វ្យា (City of Philadelphia Youth Programs)** (www.phila.gov/youthprograms)- សូមចូលរួម «កម្មវិធីនៅរដូវក្តៅនៃទីក្រុងហ្វីឡា ដែលសប្បាយរីករាយ និងមានសុវត្ថិភាព (Fun, Safe Philly Summer)» ដែលឥតគិតថ្លៃ ឬមានតម្លៃថោក។ តាមការសហការជាមួយសាលាក្រុងហ្វីឡាដែលហ្វ្យា កម្មវិធីនៅរដូវក្តៅនឹងប្រព្រឹត្តទៅនៅតាមសាលារបស់យើងជាច្រើន។ ហើយមានផ្តល់អាហារនៅរដូវក្តៅដល់ក្មេងដែលមានអាយុ១៨ឆ្នាំ និងក្មេងជាងនេះ។ សូមមើលវិបសៃ www.phillysummermeals.com ឬទូរស័ព្ទទៅលេខ ៣១១ ដើម្បីស្វែងរកទីកន្លែងដែលផ្តល់អាហារនៅរដូវក្តៅ ដែលនៅជិតជាងគេ។

- **ដៃគូសម្រាប់សកម្មភាពក្រោយម៉ោងសិក្សា (ASAP/After School Activities Partnerships) (www.phillyasap.org) --** កម្មវិធីក្រោយម៉ោងសិក្សាជាច្រើន នឹងបើកសម្រាប់កម្មវិធីនៅរដូវក្តៅ។ សម្រាប់ព័ត៌មានលម្អិត សូមចុចលើពាក្យ "Directory." ព័ត៌មានអំពីកម្មវិធីនីមួយៗ គឺសម្រាប់តែឆ្នាំសិក្សានេះ ដូច្នេះសូមទាក់ទងទៅកន្លែងនីមួយៗផ្ទាល់ ដើម្បីសុំព័ត៌មានអំពីកម្មវិធីដែលមាននៅរដូវក្តៅ។

- **អង្គការ United Way នៃតំបន់ជុំវិញទីក្រុងហ្វីឡាដែលហ្វ្យា និងប៉ែកខាងត្បូងនៃរដ្ឋនូជឺស៊ី** វិបសៃ (http://211sepa.org) ផ្តល់ព័ត៌មានតាមអ៊ិនធ័រណិតអំពី បញ្ជីឈ្មោះកម្មវិធីនៅរដូវក្តៅ។ លោកអ្នកអាចចុចចូលមើលបញ្ជីឈ្មោះបាននៅក្នុងវិបសៃ www.nj211.org/sepa/images/SummerCampActivityPrograms2013.pdf ។ បើសិនជាលោកអ្នកគ្មានអ៊ិនធ័រណិត សូមទូរស័ព្ទទៅលេខ ២-១-១- ឬ ៨៦៦-៩៦៤-៧៩២២ ដើម្បីសុំជំនួយ។

យើងខ្ញុំសូមឲ្យលោកអ្នកចាប់ផ្តើមរៀបចំគម្រោងការឥឡូវនេះ ដោយសារកម្មវិធីជាច្រើនទទួលអ្នកចូលរួម តាមលេខរៀងដែលមកចុះឈ្មោះបានមុន។ សូមចែកចាយព័ត៌មានទាំងនេះដល់មិត្តភ័ក្ក និងអ្នកជិតខាង ទាំងអស់។

ដោយសេចក្តីស្មោះត្រង់



William R. Hite, Jr., Ed.D.